មាតិកា


១. សិក្ខាកាមសរុបចំនួន៤៧៤នាក់ បានចូលរួមវគ្គបំប៉នលើ ឯកសារណែនាំអំពីការដឹកនាំសាលារៀនដែលឆ្លើយតបនឹងយេនឌ័រ
២. ការធ្វើស្វ័យវាយតម្លៃសាលារៀនដែលឆ្លើយតបនឹងយេនឌ័រលើកដំបូងបានបញ្ចប់
៣. ការចែករំលែកស្តីពីវឌ្ឍនភាពគម្រោងTIGER ដល់ក្រុមគាំទ្រវិស័យអប់រំនៅខេត្តបាត់ដំបង (BEST)
៤. ម្ចាស់ជំនួយរបស់ពួកយើង
៥. ទំនាក់ទំនង


TIGER
លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន
TEACHING FOR IMPROVED GENDER EQUALITY AND RESPONSIVENESS

## សិក្ខាកាមសរុបចំនួន៤៧៤នាក់ បានចូលរួមវគ្គបំប៉នលើ ឯកសារណែនាំអំពីការដឹកនាំសាលារៀនដែលឆ្លើយតបនឹងយេនឌ័រ

ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ ខែមិថុនា ឆ្នាំ២០១៩ មាន**វគ្គបណ្តុះបណ្តាលចំនួន១៣វគ្គ** ស្តីពីភាពជាអ្នកដឹកនាំសាលារៀន និងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រត្រូវបានរៀបចំឡើងប្រកបដោយជោគជ័យ។ គ្រូបង្រៀន ថ្នាក់ដឹកនាំសាលា និងសមាជិកគណៈកម្មការទ្រទ្រង់សាលាចំនួន ៤៧៤ នាក់ (ស្រី ២៦៩) នៃសាលាបឋមសិក្សា និងមធ្យមសិក្សាចំនួន២០ ត្រូវបានបណ្តុះបណ្តាលពី ការឆ្លើយតបនឹងយេនឌ័រ និងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតាមសាលារៀន។ វគ្គបំប៉ននេះត្រូវបានធ្វើឡើងដោយក្រុមការងារដែលមានការជម្រុញទឹកចិត្តខ្ពស់ដែលរួមមាន គ្រូឧទ្ទេសមកពីវិទ្យាស្ថានគរុកោសល្យបាត់ដំបង និងសមាជិកតំណាងមកពីក្រុមគម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន (TIGER )។

សិក្ខាកាម **បានយល់ដឹងពីឯកសារណែនាំស្តីពី ភាពជាអ្នកដឹកនាំសាលារៀន និងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ ហើយសមត្ថភាពរបស់ពួកគេក្នុងការបង្កើតសាលារៀនដែលឆ្លើយតបនឹងយេនឌ័រត្រូវបានពង្រឹង។** ពួកគេក៏បានពិភាក្សាអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតាមសាលារៀន ឆ្លុះបញ្ចាំងពីឥរិយាបថ និងបានគិតយ៉ាងសកម្មលើរបៀបកែលម្អសាលារៀនរៀងៗខ្លួនផងដែរ។ សិក្ខាកាមបានកោតសរសើរចំពោះវិធីសាស្ត្របែបចូលរួមដែលបានប្រើក្នុងវគ្គបំប៉ននេះ ។

> សិក្ខាកាមជាគ្រូបង្រៀនម្នាក់បានបង្ហាញចំណាប់អារម្មណ៍ពីវគ្គបំប៉ននេះថា:
> **"ខ្ញុំគិតថាយេនឌ័រគឺវាមានភាពសាមញ្ញមែនទែន ប៉ុន្តែឥឡូវ ខ្ញុំយល់ថាវាពិតជាមានសារៈសំខាន់ណាស់ដែលត្រូវយល់ដឹងអំពីផ្នត់គំនិតយេនឌ័រនៅក្នុងថ្នាក់រៀន និងសង្គមទូទៅ។ ខ្ញុំចូលចិត្តក្នុងការចែករំលែកគំនិតក្នុងអំឡុងពេលចូលរួមវគ្គបំប៉ននេះ "** ។

ដើម្បីវាស់វែងពីផលជះនៃវគ្គបណ្តុះបណ្តាលនេះ យើងបានធ្វើតេស្តមុនវគ្គ និងក្រោយវគ្គជាមួយសិក្ខាកាម។ លទ្ធផលបានបង្ហាញថាមានការកើនឡើងនៃចំណេះដឹងរបស់សិក្ខាកាមអំពីយេនឌ័រ និងការអប់រំ។ លទ្ធផលមុនវគ្គបង្ហាញថា សិក្ខាកាមចំនួន **១០១នាក់ មានការយល់ដឹងយ៉ាងច្បាស់អំពីយេនឌ័រ** ។ **បន្ទាប់ពីទទួលបានវគ្គបំប៉នរួចមក សិក្ខាកាមចំនួន ៤៦៥ នាក់** មានការយល់ដឹងយ៉ាងច្បាស់អំពីយេនឌ័រ។
នៅពេលដែលសិក្ខាកាមចាប់ផ្តើមធ្វើការអនុវត្តឯកសារណែនាំនៅក្នុងសាលារៀនរៀងៗខ្លួន ពួកគេនឹងទទួលបានការបង្វឹកផ្ទាល់ពេលបំពេញការងារ ដើម្បីដោះស្រាយបញ្ហាដែលពួកគេជួបប្រទះ។





## ការធ្វើស្វ័យវាយតម្លៃសាលារៀនដែលឆ្លើយតបនឹងយេនឌ័រលើកដំបូងបានបញ្ចប់

ផ្អែកលើគោលការណ៍នៃឯកសារណែនាំ ការធ្វើស្វ័យវាយតម្លៃយេនឌ័របានធ្វើ**នៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង នៅសាលារៀនចំនួន២០ នៃគម្រោង TIGER និងសាលារៀនរបស់អង្គការសង្គមស៊ីវិលចំនួន ១៦** ។ ការវាយតម្លៃការឆ្លើយតបសមភាពយេនឌ័ររបស់សាលានីមួយៗមាន៤កម្រិតខុសៗគ្នា គឺមានកម្រិតគ្មានសមភាពយេនឌ័រ ទាប មធ្យម និងកម្រិតខ្ពស់ ។
តាមរយៈការធ្វើស្វ័យវាយតម្លៃការឆ្លើយតបនឹងយេនឌ័រ សាលារៀនចំនួន២ ទទួលបានពិន្ទុទាបបំផុត គឺមិនមានសមភាពយេនឌ័រ ។ សាលារៀនចំនួន ៣៤ ផ្សេងទៀតត្រូវបានដាក់ពិន្ទុស្ថិតក្នុងការឆ្លើយតបនឹងសមភាពយេនឌ័រកម្រិតទាប។ សាលារៀនអាចកែលម្អឱ្យប្រសើរឡើងនូវផ្នែកចំនួន៣ គឺវិធីសាស្ត្របង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ រចនាសម្ព័ន្ធសាលារៀនឆ្លើយតបនឹងសមភាពយេនឌ័រ និងភាពជាដៃគូជាមួយសហគមន៍។ លទ្ធផលនៃការវាយតម្លៃ ត្រូវបានចែករំលែកជាមួយសាលារៀនរៀងៗខ្លួន និងចំណុចជាក់លាក់ត្រូវបានលើកយកមកពិភាក្សាដើម្បីកែលម្អ។

ជាទូទៅសាលារៀនទទួលបានពិន្ទុមធ្យមប្រហែល ៤១% តែប៉ុណ្ណោះនៃកម្រិតសមភាពយេនឌ័រ ដែលមានន័យថា **សាលារៀនភាគច្រើនមានសមភាពយេនឌ័រកម្រិតទាបនៅឡើយ** ។
ប្រសិនបើក្រឡេកមើលលទ្ធផលលម្អិតលើផ្នែកនីមួយៗ នៃការវាយតម្លៃការឆ្លើយតបនឹងសមភាពយេនឌ័រ ពិន្ទុមធ្យមដែលសាលាទទួលបានលើវិធីសាស្ត្របង្រៀន និងរៀនដែលឆ្លើយតបនឹងយេនឌ័រមាន៥០% សាលាដែលមានរចនាសម្ព័ន្ធសាលារៀនដែលឆ្លើយតបនឹងយេនឌ័រមាន ៣៧% (មានគុណភាពយេនឌ័រ) ចំណែកឯសាលាដែលមានភាពជាដៃគូជាមួយសហគមន៍មាន៣២% ។
សាលារៀនទាំងអស់ត្រូវបានគាំទ្រដោយក្រុមគម្រោងតាមរយៈ**ការផ្តល់ការបង្វឹកផ្ទាល់ជាបន្តបន្ទាប់** រួមទាំងការផ្តល់វគ្គរំលឹកស្តីពី ការវាយតម្លៃនៅខែបន្ទាប់ៗ ។ ការបង្វឹកផ្ទាល់ នឹងសង្កត់ធ្ងន់លើចំណុចដែលសាលាទទួលបានពិន្ទុទាបខ្លាំង ហើយត្រូវយកចិត្តទុកដាក់ជាពិសេសសម្រាប់ធ្វើការងឲ្យប្រសើរឡើង។ នៅពេលការធ្វើស្វ័យវាយតម្លៃ ទទួលបាននូវលទ្ធផលវិជ្ជមាន **សាលារៀនអាចត្រូវបានគេទទួលស្គាល់ថាជាសាលារៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ** ។




## ការចែករំលែកស្តីពីវឌ្ឍនភាពគម្រោង TIGER ដល់ក្រុមគាំទ្រវិស័យអប់រំនៅខេត្តបាត់ដំបង (BEST)

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ **ក្រុមគម្រោងបានបង្ហាញពីវឌ្ឍនភាពនៃគម្រោង TIGER** ក្នុងកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមគាំទ្រវិស័យការអប់រំខេត្តបាត់ដំបង (BEST) ។ អ្នកចូលរួមកិច្ចប្រជុំនេះ គឺជាសមាជិករបស់ក្រុមគាំទ្រវិស័យអប់រំខេត្តបាត់ដំបង (BEST) ដែលមានបំណងស្វែងរកកិច្ចសហប្រតិបត្តិការ និងការសហការគ្នារវាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអង្គការសង្គមស៊ីវិលនៅក្នុងវិស័យអប់រំ។ អ្នកចូលរួមសរុបចំនួន ៤០ នាក់ (ស្រី ១៩ នាក់) បានចូលរួមព្រឹត្តិការណ៍ដ៏ជោគជ័យនេះ។

លោក ឈួន ចំរើន (មកពីអង្គការ PKO) បានចែករំលែកអំពីសកម្មភាពគម្រោង TIGER ដែលបានជួយគាំទ្រដល់ការបង្កើតសាលារៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ លោកបានសង្កត់ធ្ងន់ថា សិស្សនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សាទាំងអស់ត្រូវការការការពារពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតាមសាលារៀន ដែលអាចជួយឱ្យពួកគេមានការចូលរួមប្រកបដោយសមធម៌ក្នុងគ្រប់សកម្មភាពទាំងអស់នៅសាលារៀន និងនៅផ្ទះ។ តាមរយៈការពិភាក្សាអំពីសមិទ្ធផល និងដំណើរការនៃគម្រោង TIGER គាត់បាន**ជម្រុញលើកទឹកចិត្ត ដល់សមាជិករបស់ក្រុមគាំទ្រវិស័យការអប់រំខេត្តបាត់ដំបង (BEST) ផងដែរ** ។

## ម្ចាស់ជំនួយរបស់គម្រោង

EUROPEAN UNION

Belgium partner in development

Flanders State of the Art

អាសយដ្ឋាន៖ ផ្ទះលេខ B-53, ភូមិកម្មករ, សង្កាត់ស្វាយប៉ោ,
ក្រុង-ខេត្តបាត់ដំបង, ប្រទេសកម្ពុជា។
គេហទំព័រ៖ www.cambodia.vvob.be/tiger
ស្វែងរកពួកយើងតាមរយៈហ្វេកបុក៖ @vvobcambodia, @kapeaction,
@gadccambodia, @pkoorganization

ព្រឹត្តិប័ត្រព័ត៌មាននេះ ផលិតដោយមានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។
ខ្លឹមសារដែលមានក្នុងព្រឹត្តិប័ត្រនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់
អង្គការ VVOB, GADC, PKO និង KAPE ហើយវាមិនឆ្លុះបញ្ចាំងពីទស្សនៈ
របស់សហភាពអឺរ៉ុបឡើយ។ រដ្ឋាភិបាលបែលហ្ស៊ិកមិនអាចទទួលខុសត្រូវ
ចំពោះខ្លឹមសាររបស់ព្រឹត្តិប័ត្រព័ត៌មាននេះដែរ។